# ដំណើរការល្អប្រសើររបស់គណៈកម្មការទ្រទ្រង់សាលារៀន នាំឱ្យអត្រាបោះបង់ការសិក្សាមានការធ្លាក់ចុះ

ដោយទទួលបានការបំពាក់បំប៉នចំណេះដឹង សមាជិកគណៈកម្មការទ្រទ្រង់សាលារៀនបានចុះទៅតាមផ្ទះសិស្សដែលអវត្តមានដើម្បីជួយពួកគេកុំឱ្យបោះបង់ការសិក្សា។

អ៊ីវ សុខខឿន ជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន និងជាអនុប្រធានភូមិ។ គាត់មានចៅ ៤នាក់រៀននៅសាលាបឋមសិក្សាពូហ្យាម ខេត្តមណ្ឌលគិរី គាត់ចង់ឱ្យពួកគេទទួលបានការអប់រំដែលមានគុណភាពល្អបំផុត។ នេះជាមូលហេតុមួយដែលរៀងរាល់ថ្ងៃគាត់បានឈប់ហើយឈៀងចូលសាលារៀនដើម្បីពិនិត្យវត្តមានគ្រូ និងសិស្សនៅពេលគាត់ធ្វើដំណើរទៅធ្វើការ។

គាត់និយាយថា ៖ "ខ្ញុំចូលរួមតាមដានសាលា ព្រោះខ្ញុំចូលចិត្តការអប់រំ និងចង់ឱ្យសាលានេះក្លាយជាសាលាល្អ។ វាសំខាន់សម្រាប់ខ្ញុំក្នុងការតាមដានសិស្ស និងរកមូលហេតុនៃអវត្តមានរបស់ពួកគេ"។

ដោយបានធ្វើជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនអស់រយៈពេលពីរបីឆ្នាំ គាត់ទទួចពន្យល់ថា នៅមុនពេលវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដែលគាត់បានចូលរួមគណៈកម្មការនេះមិនមានភាពសកម្មខ្លាំងទេ។

គាត់រៀបរាប់ថា ៖ "ខ្ញុំបានរៀនអំពីការទទួលខុសត្រូវពីវគ្គបណ្តុះបណ្តាលនានា និងពីទស្សនកិច្ចសិក្សាដែលអង្គការឃែរបានបញ្ជូនខ្ញុំទៅកាន់សាលាបឋមសិក្សាមួយក្នុងខេត្តកំពត ដែលនៅទីនោះខ្ញុំបានឃើញសាលារៀនមានដំណើរការល្អពេលមានការចូលរួមពីសហគមន៍"។

ដោយហេតុថាឥឡូវនេះគាត់ដឹងពីវិធីជួយសាលាបឋមសិក្សាក្នុងភូមិរបស់គាត់ ដូច្នេះហើយទើបរាល់ពេលសិស្សអវត្តមាន គាត់តែងតែចុះទៅដល់ផ្ទះពួកគេដើម្បីរកមូលហេតុ។

គាត់និយាយថា ៖ "ការធ្វើដូច្នេះគឺ ខ្ញុំចង់ជួយសហគមន៍ និងផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំដល់ម្តាយឪពុក"។

គាត់គូសបញ្ជាក់ថា ៖ "ពេលខ្លះសិស្សឈប់មករៀនព្រោះពួកគេត្រូវជួយឪពុកម្តាយរបស់ពួកគេដើម្បីប្រមូលផល។ ពេលខ្លះទៀតពួកគេរៀនយឺតហើយពួកគេក៏ឈប់មករៀនព្រោះពួកគេខ្មាស"។

ដោយមិនគិតពីមូលហេតុនេះ គាត់នៅគ្រប់ពេលវេលាទាំងអស់ បានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីនិយាយជាមួយឪពុកម្តាយរបស់សិស្សដែលបោះបង់ការសិក្សា។

[គាត់និយាយថា] ៖ "ខ្ញុំនិយាយជាមួយឪពុកម្តាយ និងសិស្សនៅពេលពួកគេចង់បោះបង់ការសិក្សា។ ខ្ញុំនិយាយជាមួយពួកគេអំពីសារៈសំខាន់នៃការអប់រំ។ ពេលខ្លះខ្ញុំយកសិស្សម្នាក់ទៀតមកជាមួយខ្ញុំ ហើយខ្ញុំប្រៀបធៀបសិស្សម្នាក់នេះជាមួយសិស្សដែលចង់បោះបង់ការសិក្សា និងពន្យល់ពីអត្ថប្រយោជន៍ដែលសិស្សនេះមានច្រើនជាងកុមារដែលមិនទទួលបានការអប់រំ"។



© Nicolas Axelrod / Ruom / CARE

*"ខ្ញុំនិយាយជាមួយឪពុកម្តាយ និងសិស្សនៅពេលពួកគេចង់បោះបង់ការសិក្សា។ ខ្ញុំនិយាយជាមួយពួកគេអំពីសារៈសំខាន់នៃការអប់រំ។ ពេលខ្លះខ្ញុំយកសិស្សម្នាក់ទៀតមកជាមួយខ្ញុំ ហើយខ្ញុំប្រៀបធៀបសិស្សម្នាក់នេះជាមួយសិស្សដែលចង់បោះបង់ការសិក្សា និងពន្យល់ពីអត្ថប្រយោជន៍ដែលសិស្សនេះមានច្រើនជាងកុមារដែលមិនទទួលបានការអប់រំ"។*

ហើយនេះហាក់ដូចជា ថាគាត់មិនមែនជាសមាជិកតែម្នាក់ក្នុងជួរគណៈកម្មការទ្រទ្រង់សាលារៀនក្នុងខេត្តមណ្ឌលគិរី ដែលបានចាត់ទុកថាការរក្សាកុមារឱ្យនៅបន្តការសិក្សាជាអាទិភាពរបស់គាត់តែម្នាក់ឯងនោះទេ ក្នុងនោះក៏មាននាយក នាយិកានៅតាមសាលាបឋមសិក្សាជាច្រើនទៀត បានធ្វើឱ្យអត្រាបោះបង់ការសិក្សាធ្លាក់ចុះដែរ។ ការធ្លាក់ចុះនូវអត្រាបោះការសិក្សាបាននាំឱ្យសមាជិកគណៈកម្មការមានការប្តេជ្ញាចិត្ត និងធ្វើសកម្មភាព។

ឧទាហរណ៍៖ ថែម សុភ័ក្រ្ត នាយិកាសាលាបឋមសិក្សាពូហ្យាម ពន្យល់ដោយមោទនភាពថា ឆ្នាំនេះគ្មានសិស្សបោះបង់ទេ មានសិស្ស៥នាក់បានផ្ទេរទៅរៀនសាលាផ្សេង ឯឆ្នាំមុនមានសិស្ស ៧នាក់ឈប់រៀន។

ស្រដៀងគ្នានេះដែរ ស៊ុន ម៉ៅ នាយកសាលាបឋមសិក្សា ដាក់ដាំនិយាយថា ឆ្នាំនេះមានសិស្សបោះបង់ការសិក្សាចំនួន១៤នាក់ បើប្រៀបធៀបពីឆ្នាំ២០១៥ មានចំនួនបោះបង់ការសិក្សាចំនួន ៣០នាក់។

ឧទាហរណ៍ពីសាលារៀនទាំងនេះក្នុងខេត្តមណ្ឌលគិរីបង្ហាញនូវអ្វីដែលការស្រាវជ្រាវក្នុងខេត្តរតនគិរី បានបញ្ជាក់រួចមកហើយថាការបណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលារៀនអាចនាំឱ្យសិស្សក្នុងចំនួនច្រើននៅបន្តការសិក្សា។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

សហភាពអឺរ៉ុប SWEDEN unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

*© CARE Cambodia, September 2016*